00533215

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ/No: D365/2/10

តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី
ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម
ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៦៧)**

**ចំពោះមុខ៖** **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Catherine MARCHI-UHEL**
**ចៅក្រម ហួត វុទ្ធី**

**កាលបរិច្ឆេទ៖** **ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 06 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សាធារណៈ**

# សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមនៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក ពេជ្រ សម្បត្តិ
លោក Anees AHMED

**ជនត្រូវចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

## សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

លោក នី ច័ន្ទឌី

លោក Madhev MOHAN

លោកស្រី Lima NGUYEN

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Elizabeth-Joelle RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Martine JACQUIN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រី Françoise GAUTRY

លោកស្រី Isabelle DURAND

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោក Ferdinand DJAMMEN-NZEPA

លោក ឡៅ ជុនធី

លោកស្រី ស៊ីន សុវន

លោក សំ សុគង់

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គង់ ហេង

កញ្ញា Silke STUDZINSKY

លោក Olivier BAHOUGNE

លោកស្រី Marie GUIRAUD

លោក Patrick BAUDOUIN

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក Julien RIVET

លោក Pascal AUBOIN

## ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង

## សហមេធាវីការពារក្តីជនត្រូវចោទ

សុន អរុណ

Michel PESTMAN

Victor KOPPE

អាង ឧត្តម

Michael KARNAVAS

ស ស្វវាន

Jacques VERGES

## សហចៅក្រមស៊ើបអង្កេត

លោក យូ ប៊ុនឡេង

លោក Marcel LEMONDE

00533217



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **"អ.វ.ត.ក"** ទទួលបានបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ("ភាគីប្ដឹងឧទ្ធរណ៍") ជាការ "ឆ្លើយតបទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងសំណើសុំដាក់បញ្ចូលឯកសារភ័ស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ("បណ្ដឹងឧទ្ធរណ៍")[១]។

## សេចក្ដីផ្ដើម

១ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់សំណើមួយទៅសហចៅក្រមស៊ើបអង្កេតស្នើសុំដាក់បញ្ចូលឯកសារភ័ស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ("សំណើ")"[២]។

២ នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចទាក់ទងនឹងសំណើសុំដាក់បញ្ចូលឯកសារភ័ស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង("ដីកាសម្រេច")[៣]នេះ។ ដីកានេះត្រូវបានជូនដំណឹងទៅភាគីនៅថ្ងៃដដែល គឺថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០។

៣ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់សេចក្ដីជូនដំណឹងនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនោះ និងនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ពួកគេបានដាក់បណ្ដឹងឧទ្ធរណ៍។

[១] សារណាបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីការសុំដាក់ឯកសារភស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ឯកសារ D365/2/1។

[២] សំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលឯកសារភស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D365

[៣] ដីកាសម្រេចស្ដីពីសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលឯកសារភស្ដុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ឯកសារ D365/1។

៤ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានកំណត់កាលបរិច្ឆេទនៃសវនាការសម្ងាត់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នោះ។ សវនាការនេះបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ "ដោយភ្ជាប់លក្ខខណ្ឌដែលអង្គបុរេជំនុំជម្រះទទួលសេចក្តីជូនដំណឹង [អំពីចេតនាធ្វើសារណាផ្ទាល់មាត់] ពីអ្នកឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[៤]។" នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់លោក អៀង សារី បានដាក់សេចក្តីជូនដំណឹងអំពីចេតនាបង្ហាញសារណាផ្ទាល់មាត់ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[៥]។ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់លោក នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីចេតនាធ្វើសារណាផ្ទាល់មាត់ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[៦]។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន បានបញ្ជាក់អំពីចេតនារបស់ខ្លួនក្នុងការធ្វើសារណាផ្ទាល់មាត់ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍[៧]។

៥ នៅថ្ងៃទី២៦ និង២៧ ខែឧសភា ឆ្នាំ២០១០ សវនាការសម្ងាត់លើបណ្តឹងឧទ្ធរណ៍ ត្រូវបានរៀបចំឡើងនៅចំពោះជនត្រូវចោទ។ អង្គបុរេជំនុំជម្រះបានស្តាប់ការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នោះ ពីសំណាក់សហមេធាវីការពារក្តីរបស់លោក អៀង សារី លោក នួន ជា និងលោក ខៀវ សំផន និងចុងក្រោយមានការឆ្លើយតបមកវិញពីភាគីប្តឹងឧទ្ធរណ៍ផងដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានទទួលសេចក្តីជូនដំណឹងស្តីពីចេតនារបស់សហមេធាវីការពារក្តីរបស់លោក ខៀវ សំផន ដែលចង់ឲ្យអង្គបុរេជំនុំជម្រះស្តាប់សារណារបស់ពួកខ្លួន ប៉ុន្តែសេចក្តីជូនដំណឹងនោះបានដាក់ហួសពេលកំណត់។ ទោះជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា * ECCC * CETC * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

[៤] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ឯកសារ D365/2/2។

[៥] សេចក្តីជូនដំណឹងរបស់លោក អៀង សារី អំពីគោលបំណងឲ្យមានការដេញដោលនាពេលសវនាការទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ កសព ទាក់ទងនឹងការសុំដាក់ភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលគាំទ្រការបញ្ជាក់ការដឹងឮរបស់ជនត្រូវចោទអំពីឧក្រិដ្ឋកម្ម ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ឯកសារ D365/2/5។

[៦] សេចក្តីជូនដំណឹងពីចេតនាចូលរួមសវនាការ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ឯកសារ D365/2/6។

[៧] សារអេឡិចត្រូនិច ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ មកពីតំណាងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

យ៉ាងនេះក្តីដោយពុំចាំបាច់មានសំណើ អង្គបុរេជំនុំជម្រះសម្រេចព្រមទទួលយកសេចក្តីជូនដំណឹងនោះ ដើម្បីធានារក្សាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទ ខៀវ សំផន[៨]។

## ភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៦ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០។ ដីកាសម្រេចនេះត្រូវបានជូនដំណឹងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០។ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១០ ដែលស្ថិតក្នុងរយៈពេលកំណត់ដែលមានចែងក្នុងវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង ("វិធាន") ដោយពិចារណាអំពីថ្ងៃបុណ្យជាតិថ្ងៃទី១៤ ១៥ និង១៦ ខែមេសា ឆ្នាំ២០១០។ សារណាលើបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ពោលគឺនៅក្នុងអំឡុងពេលដូចមានចែងក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង")។

៧ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ដោយអនុលោមទៅតាមវិធាន ៧៤(២)[៩] ដែលចែងថាសហព្រះរាជអាជ្ញាអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងរាល់ដីកាសម្រេចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## ដីកាសម្រេច

៨ ភាគីប្តឹងឧទ្ធរណ៍បានដាក់សំណើមួយ "ស្នើសុំដាក់ឯកសារភ័ស្តុតាងបន្ថែមបញ្ចូលទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង" នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០១០។ សំណើនេះពាក់ព័ន្ធនឹងឯកសារចំនួន ២៦៨។ ដីកាសម្រេចបានណែនាំអំពីការព្រមទទួលយកឯកសារចំនួន ៧០ ឲ្យដាក់បញ្ចូលទៅក្នុងសំណុំរឿង និងបដិសេធឯកសារចំនួន ១៩៨។

---

[៨] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ (ឯកសារ D365/2/2) ត្រូវបានជូនដំណឹងទៅកាន់ភាគីទាំងឡាយនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ដដែល។

[៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២។

៩ សម្អាងហេតុដែលបានបញ្ជាក់ក្នុងដីកាសម្រេចនោះមានលក្ខណៈសង្ខេប និងសូមលើកយកបង្ហាញជូនទាំងស្រុងដូចខាងក្រោមនេះ៖

**"សំអាងហេតុនៃសេចក្តីសម្រេច"**

១ ក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវសំណុំឯកសារដែលរួមមានអត្ថបទពីប្រភពសាធារណៈ ដែលដកស្រង់ចេញពីសារព័ត៌មានអន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធនៃរបបខ្មែរក្រហម។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាឯកសារទាំងអស់នេះនឹងជួយដល់ការលាតត្រដាងការពិត ដោយសារតែវាមានការពាក់ព័ន្ធ និងមានតម្លៃភស្តុតាង ទាក់ទិននឹងបទចោទប្រកាន់មួយចំនួនដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

២ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានយ៉ាងលម្អិតអំពីភាពជាប់ពាក់ព័ន្ធរវាងឯកសារទាំងនេះជាមួយនឹងបទចោទប្រកាន់ដែលមាននៅក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាក៏បានពន្យល់ផងដែរ ថាតើឯកសារអស់ទាំងនេះអាចជួយលាតត្រដាងការពិតបានដោយរបៀបណា។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេចថា សំណើនេះមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដើម្បីធ្វើការពិចារណា។

៣ ទាក់ទិននឹងសំណើនានាលើការសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង សហចៅក្រមស៊ើបអង្កេតសូមបញ្ជាក់ជាថ្មីឡើងវិញថា ខ្លួនបានអនុវត្តនូវការវិភាគតាមផ្លូវច្បាប់ទៅលើឯកសារដែលបានស្នើទាំងនោះ ដើម្បីសម្រេចថាតើឯកសារទាំងនោះអាចជួយលាតត្រដាងការពិតបានដែរឬយ៉ាងណា។ សហចៅក្រមស៊ើបអង្កេត ដោយពិចារណាថាតើភស្តុតាងទាំងនោះមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុដែលស្ថិតក្រោមកិច្ចស៊ើបសួរដែរឬអត់ បានផ្តល់នូវការចាប់អារម្មណ៍ជាពិសេសទៅលើភស្តុតាងដោះបន្ទុក។ ប៉ុន្តែការនេះកម្រិតត្រឹមតែបញ្ហាណាដែលសហចៅក្រមស៊ើបអង្កេតបានទទួលប៉ុណ្ណោះ (រួមមានធាតុផ្សំនៃយុត្តាធិការ ឬទម្រង់នៃការទទួលខុសត្រូវ)។ បន្ថែមលើនេះសហចៅក្រមស៊ើបអង្កេត ក៏ធ្វើការពិចារណាថាតើភស្តុតាងទាំងនោះដូចគ្នា ឬក៏អត់ទៅនឹងភស្តុតាងនានាដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចគ្នា ហើយដែលបានដាក់បញ្ចូលរួចរាល់ហើយទៅក្នុងសំណុំរឿង។

៤ ទាក់ទងទៅនឹងអត្ថបទសារព័ត៌មានដែលផ្តោតជាពិសេសលើការប្រព្រឹត្តិចំពោះពុទ្ធសាសនិក ការអនុវត្តការរៀបការដោយបង្ខំ ការជម្លៀសប្រជាជនចេញពីរាជធានីភ្នំពេញ ការរំលោភលើផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ ការទទួលខុសត្រូវចម្បងរបស់ជនត្រូវចោទ វត្តមាននៃជម្លោះប្រដាប់អាវុធជាអន្តរជាតិជាមួយប្រទេសវៀតណាម និងអត្ថបទដទៃទៀតដែលសរសេរដោយសាក្សីរបស់សហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលស៊ើបសួរ សហចៅក្រមស៊ើបអង្កេតពិចារណាថាអត្ថបទទាំងអស់នេះមានការពាក់ព័ន្ធគ្រប់គ្រាន់ទៅនឹងទិដ្ឋភាពអង្គហេតុមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេតបានទទួល។ ហេតុដូច្នេះឯកសារទាំងអស់នោះអាចទទួលយកបាន ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿង។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៩ ចំពោះឯកសារដែលនៅសល់ សហចៅក្រមស៊ើបអង្កេតមិនអាចសម្រេចបានថាតើឯកសារទាំងនោះមានភាពពាក់ព័ន្ធបែបណាទេ នៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរបច្ចុប្បន្ន ព្រោះថាឯកសារទាំងនោះមិនផ្តោតជាពិសេសទៅលើចំណុចណាមួយនៃកិច្ចស៊ើបសួរឡើយ។ ឯកសារមួយចំនួនទៀតត្រូវបានរៀបរាប់តែបញ្ជាទូទៅប៉ុណ្ណោះ។ ដូច្នេះសហចៅក្រមស៊ើបអង្កេត សម្រេចមិនដាក់បញ្ចូលឯកសារអស់ទាំងនោះទៅក្នុងសំណុំរឿងនោះទេ ប៉ុន្តែខ្លួនអនុញ្ញាតឲ្យដាក់ឯកសារទាំងនោះទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ដែលអាចឲ្យភាគីទាំងអស់ស្វែងរកបាន។

## ការបដិសេធជាបឋម

១០ សហមេធាវីរបស់លោក អៀង សារី បានបដិសេធទៅនឹងសំណើនោះ ពោលគឺទាំងមូលដ្ឋាននៃរបៀប និងលទ្ធផលនៃសំណើទាំងមូលតែម្តង។ ពួកគាត់បានលើកឡើងថា សកម្មភាពដែលភាគីប្តឹងឧទ្ធរណ៍ធ្វើជាមុន ក្នុងការប្រមូលឯកសារចំនួន ២៦៨ នេះ គឺចាត់ថាកិច្ចស៊ើបសួរមួយ និងមិនត្រូវអនុញ្ញាតឲ្យធ្វើបានឡើយ។ ភាគីប្តឹងឧទ្ធរណ៍បានឆ្លើយតបនឹងបញ្ហានេះ នៅក្នុងកថាខណ្ឌទី៤ នៃសំណើរបស់ខ្លួនដូចតទៅ៖

> "នៅក្រោមក្របខណ្ឌនីតិវិធីនៃ អ.វ.ត.ក ទោះបីជាភាគីមិនត្រូវបានគេអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតក៏ដោយ ក៏ពួកគេអាចធ្វើការស្រាវជ្រាវបឋមដូច្នេះបានដែរ ដោយសារការនេះមានភាពចាំបាច់សម្រាប់ ពួកគេក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព ដើម្បីដាក់សំណើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ។ ពោលគឺ សហចៅក្រមស៊ើបអង្កេតលើកឡើងថា "ភាគីមានសេរីភាពពេញលេញក្នុងការពិនិត្យឡើងវិញនូវឯកសារណាមួយពីប្រភពសាធារណៈ ដើម្បីស្រាវជ្រាវរកភ័ស្តុតាងរបស់ខ្លួន និងប្រសិនបើចាំបាច់ ធ្វើការស្នើសុំទៅសហចៅក្រមស៊ើបអង្កេតសុំដាក់បញ្ចូលភ័ស្តុតាងនេះទៅក្នុងសំណុំរឿងបាន។ ការស្រាវជ្រាវបឋមបែបនេះ ពុំប៉ះពាល់ដល់ការហាមឃាត់ភាគីក្នុងការបំពេញការស៊ើបអង្កេតរបស់ខ្លួនបាននោះទេ"។

១១ នៅក្នុងអនុស្សរណៈអន្តរការិយាល័យ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១០ ផ្ញើជូនទៅភាគីនៃសំណុំរឿងលេខ ២ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ដោយអន្លើនៅក្នុងកថាខណ្ឌទី៣ថា "... ពុំមានបទបញ្ញត្តិណាមួយ ដែលអនុញ្ញាតឲ្យភាគីបំពេញកិច្ចស៊ើបសួរជំនួសសហចៅក្រមស៊ើបអង្កេតដូចករណីនៅក្នុងប្រព័ន្ធនីតិវិធីដទៃទៀតនោះទេ... លទ្ធភាពរបស់ភាគីក្នុងការចូលពាក់ព័ន្ធគឺត្រូវបានកំហិតនៅត្រឹមការ

ស្នើសុំដំបូងនេះ ដែលជាការចាំបាច់ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការស្នើសុំឲ្យមានកិច្ចស៊ើបសួរ"[១០]។

១២ អង្គបុរេជំនុំជម្រះរកពុំឃើញមានសកម្មភាពមិនគួរគប្បីរបស់ភាគីប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការស៊ើបអង្កេតដែលពុំត្រូវបានអនុញ្ញាតនោះទេ។ ផ្ទុយទៅវិញ ពួកគាត់បានសម្អាងតែទៅលើឯកសារដែលបានមកពី "ប្រភពសាធារណៈ" នោះប៉ុណ្ណោះសម្រាប់គាំទ្រសំណើ។ ពួកគាត់មិនបានធ្វើការស៊ើបអង្កេតណាមួយទេ ប៉ុន្តែសកម្មភាពពួកគាត់គឺដូចគ្នានឹងការស្នើសុំឲ្យទទួលយកនូវឯកសារដែលបានសម្គាល់អត្តសញ្ញាណរួចហើយ ដែលបានមកពីការស្រាវជ្រាវពីប្រភពឯកសារសាធារណៈដែលត្រូវបានអនុញ្ញាត។ សកម្មភាពនេះពុំមែនជាកិច្ចស៊ើបសួរទេ។ ការស្រាវជ្រាវបែបនេះ ត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេតយ៉ាងច្បាស់ ដូចបានទទួលស្គាល់ក្នុងកថាខណ្ឌទី១ នៃដីកាសម្រេចរបស់ពួកគាត់ដែលចែងថា "ដែលរួមមានអត្ថបទពីប្រភពសាធារណៈដែលដកស្រង់ចេញពីសារព័ត៌មាន"។ ប្រសិនបើឯកសារដែលបានស្នើសុំទាំងនោះគេរកបានដោយការស្រាវជ្រាវពីប្រភពអសាធារណៈវិញ ការធ្វើដូច្នេះវាអាចស្មើគ្នានឹងការស៊ើបអង្កេតមួយដែរ។

១៣ សហមេធាវីការពារក្តីរបស់លោក អៀង សារី និងលោក នួន ជា បានជំទាស់បន្ថែមទៀត ចំពោះពេលវេលានៃសំណើនោះ ដោយអះអាងថា វាមិនសមស្របបើយោងទៅលើការបញ្ចប់នៃកិច្ចស៊ើបសួរខាងផ្លូវតុលាការ។ ដោយមូលហេតុនេះ គេពុំគប្បីយកសំណើទាំងមូលនោះមកពិចារណានោះទេ។ សហមេធាវីការពារក្តីពុំបានយោងច្បាប់ ឬយុត្តិសាស្ត្រណាមួយ ដើម្បីគាំទ្រទឡ្ហីករណ៍របស់ខ្លួនឡើយ។ អង្គបុរេជំនុំជម្រះមិនអាចកំណត់បានដោយឯករាជ្យនូវការគាំទ្រណាមួយចំពោះចំណុចនេះទេ។ ផ្ទុយទៅវិញ ពុំមានការកម្រិតព្រំដែនដូច្នេះទៅលើភាគីណាមួយដែលដាក់សំណើបែបនេះនៅក្នុងវិធាន ៥៥(១០) នោះដែរ។ វិធាននេះ ៥៥(១០) ចែងថា សំណើដូច្នេះ គេអាចដាក់បាននៅគ្រប់ពេលវេលា។ វិធាន ៦៦(១) ចែងច្បាស់ថា "នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់" ដែលក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើដូច្នេះមែនកាលពីថ្ងៃ១៤ ខែមករា ឆ្នាំ២០១០ "...

---

[១០] អនុស្សារណៈអន្តរការិយាល័យ "សេចក្តីចម្លងនៃចម្លើយរបស់យើងចំពោះលិខិតរបស់សហមេធាវីរបស់លោក នួន ជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទិននឹងការដឹកនាំការស៊ើបអង្កេត" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ឯកសារ A110/II ទំព័រ២ កថាខណ្ឌ៣។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00533223



ភាគីទាំងអស់មានរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ ដើម្បីសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម"។ ដូច្នេះ សំណើនោះត្រូវបានអនុញ្ញាតយ៉ាងជាក់លាក់។

១៤ សហមេធាវីការពារក្តីរបស់លោក នួន ជា បានលើកឡើងបន្ថែមបន្ថែមទៀតអំពីផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិរបស់ជនត្រូវចោទពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគាត់ ក្នុងការស្នើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម នៅបន្ទាប់ពីមានការសម្រេចទទួលយកឯកសារចំនួន៧០នៅក្នុងដីកាសម្រេចរួចមក ឬការសម្រេចទទួលយកឯកសារបន្ថែមដទៃទៀតនៅក្រោយបណ្តឹងឧទ្ធរណ៍នេះ រួមទាំងឈ្មោះសាក្សី ឬប្រភពភស្តុតាងផ្សេងៗទៀតនៅក្នុងឯកសារទាំងនោះផង។ អង្គបុរេជំនុំជម្រះមិនមែនជាអ្នកដែលត្រូវសម្រេចដោះស្រាយបញ្ហានេះនៅក្នុងដំណាក់កាលនេះនោះ ទាំងសេចក្តីសម្រេចចំពោះឯកសារដែលត្រូវបានបដិសេធ និងសេចក្តីសម្រេចក្នុងការផ្តល់ ឬមិនផ្តល់ពេលវេលាបន្ថែមដើម្បីដាក់សំណើសុំកិច្ចស៊ើបសួរ គឺជាសមត្ថកិច្ចផ្ទាល់របស់សហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដោយយោងទៅលើការចេញដីកាសម្រេចទទួលយកឯកសារទាំង៧០នោះ ភាគីដែលត្រូវឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍សុខចិត្តមិនស្វះស្វែងរកការស្នើសុំពន្យារពេលបន្ថែមនោះទេ។

១៥ មិនតែប៉ុណ្ណោះ គ្រប់ភាគីនៃសំណុំរឿងលេខ២ សុទ្ធតែអាចចូលមើលប្រភពឯកសារសាធារណៈបានគ្រប់ពេលវេលាទាំងអស់។ ក្នុងពេលណាមួយក៏បាននៅមុនសេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ និងដប់ប្រាំថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងនោះ គេពុំបានហាមឃាត់ពួកគាត់ក្នុងការស្នើសុំកិច្ចស៊ើបសួរណាមួយដែលកើតចេញអំពីសម្ភារៈឯកសារប្រភេទនេះទាល់តែសោះ[១១]។ សម្ភារៈឯកសារនេះអាចមានរាប់បញ្ចូលទាំងព័ត៌មានពីប្រទេសឥណ្ឌា ប្រទេសអឺរ៉ុបខាងត្បូង (Scandinavia) និងកន្លែងផ្សេងៗទៀត ដូចដែលបានលើកឡើងដោយសហមេធាវីការពារក្តីរបស់លោក ខៀវ សំផន។ មកដល់ពេលនេះ គេមិនអាចប្តឹងតវ៉ាអំពីការមិនផ្តល់ឱកាសដល់ភាគីបានទៀតទេ ដ្បិតឱកាសបែបនេះបានបើកចំហសម្រាប់គ្រប់ភាគី អស់រយៈពេលមិនតិចជាងពីរឆ្នាំមកហើយទេ ប៉ុន្តែភាគីខ្លួនឯងមិនបានប្រើប្រាស់វា។

[១១] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ឯកសារ D317។

១៦ សហមេធាវីការពារក្តីរបស់លោក អៀង សារី បានស្នើបន្ថែមសុំឲ្យអង្គបុរេជំនុំជម្រះចេញសេចក្តីបង្គាប់បដិសេធឯកសារចំនួន៧០ ដែលបានព្រមទទួលឲ្យដាក់បញ្ចូលក្នុងសំណុំរឿងកន្លងមកក្នុងដីកាសម្រេច។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបញ្ហានេះពុំមានដាក់ទេ។ ដោយសារតែពុំមានបណ្តឹងឧទ្ធរណ៍ដូច្នេះ និងដោយអង្គបុរេជំនុំជម្រះកំពុងតែធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងភាពអាចទទួលយកបានរបស់វាតាមវិធានផ្ទៃក្នុង ភាគីពុំមានសិទ្ធិប្តឹងឧទ្ធរណ៍ដោយផ្ទាល់មាត់តបនឹងបណ្តឹងឧទ្ធរណ៍នោះទេ។ អង្គបុរេជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យលើកសំណើដូច្នេះទេ។

## សេចក្តីពិចារណាទៅលើបណ្តឹងឧទ្ធរណ៍

១៧ បណ្តឹងឧទ្ធរណ៍មានមូលដ្ឋានសំខាន់ចំនួនបី៖

១ ការអនុវត្តបទដ្ឋានមិនត្រឹមត្រូវ

២ ការវាយតម្លៃពុំបានត្រឹមត្រូវអំពីអង្គហេតុ និង

៣ ការមិនបានឆ្លើយតបនឹងអានុភាពត្រួតនៃភ័ស្តុតាងដែលមានលក្ខណៈស្រដៀងគ្នា។

### ក **<u>មូលដ្ឋានទី១៖ ការអនុវត្តបទដ្ឋានមិនត្រឹមត្រូវ</u>**

១៨ ភាគីប្តឹងឧទ្ធរណ៍បានសង្ខេបទឡ្ហីករណ៍របស់ខ្លួនពាក់ព័ន្ធនឹងមូលដ្ឋាននេះ ដូចខាងក្រោម៖

"ក្នុងការវាយតម្លៃឯកសារដែលភ្ជាប់នឹងសំណើនេះ សហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋានមិនត្រឹមត្រូវអំពី "ភាពពាក់ព័ន្ធ" របស់ឯកសារមួយដែលបទដ្ឋាននេះខុសពីបទដ្ឋាននៃការវាយតម្លៃឯកសារ "ដែលនាំទៅរកការបង្ហាញការពិតនៃអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតបានដាក់ឯកសារដែលបានស្នើសុំឲ្យស្ថិតក្រោមបទដ្ឋាននៃភាពអាចទទួលយកបាននៃឯកសារដែលគេមិនអាចយកបទដ្ឋាននេះមកអនុវត្តបានក្នុងដំណាក់កាលស៊ើបសួរឡើយ ដែលនេះរាប់ថាជាកំហុសឆ្គងផ្នែកច្បាប់។ ទោះក្នុងកាលៈទេសៈណាក៏ដោយ ការអនុវត្តបទដ្ឋានមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតមានជាប់មកជាមួយនូវសម្អាងហេតុមិនគ្រប់ជ្រុងជ្រោយទាក់ទិននឹងមូលដ្ឋាននៃការបដិសេធឯកសារទាំងនោះ។

00533225



លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយពុំបានទូលំទូលាយ និងពុំត្រឹមត្រូវអំពី "វិសាលភាពនៃកិច្ចស៊ើបសួរ" ដែលកំណត់ដោយប្រសិទ្ធិភាពនៃក្រុមប្រភេទឯកសារមួយចំនួនដែលអាចទទួលយកបានដែលអាចគាំទ្រដល់ការបញ្ជាក់អំពីការដឹងឮ ឬចេតនារបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មទាំងនោះ"[១២]។

១៩ នៅពេលសវនាការលើបណ្តឹងឧទ្ធរណ៍ ពុំមានជនត្រូវចោទណាមួយ ឬសហមេធាវីការពារក្តីរបស់ពួកគាត់ណាឡើងសម្តែងមតិ ឬធ្វើការការកត់សម្គាល់ពាក់ព័ន្ធនឹងមូលដ្ឋាននេះទេ។

២០ សហចៅក្រមស៊ើបអង្កេតបានសម្រេចនៅត្រង់កថាខណ្ឌទី៥នៃដីកាសម្រេចរបស់ខ្លួន បដិសេធឯកសារទាំងនោះ គឺពួកគាត់មិនបានទទួលយកឯកសារទាំងនោះទេ ដោយពួកគាត់រកឃើញថា ពួកគាត់ "មិនអាចសម្រេចថាតើឯកសារទាំងនោះមានភាពពាក់ព័ន្ធបែបណា នៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរបច្ចុប្បន្ន ព្រោះថាឯកសារទាំងនោះមិនផ្តោតពិសេសទៅលើចំណុចណាមួយនៃកិច្ចស៊ើបសួរឡើយ"។ សហចៅក្រមស៊ើបអង្កេតរកឃើញថា "សំណើនោះមានភាពពាក់ព័ន្ធជាក់លាក់គ្រប់គ្រាន់នឹងយកមកពិចារណា"។

២១ ភាគីប្តឹងឧទ្ធរណ៍បានអះអាងថាការយោងទៅលើការធ្វើតេស្តរក "ភាពពាក់ព័ន្ធ" ណាមួយគឺជាការខុសឆ្គង ដ្បិតការធ្វើតេស្តដែលត្រឹមត្រូវតាមឆន្ទានុសិទ្ធិនោះគឺការរកឲ្យឃើញថា តើឯកសារទាំងនោះពិតជា "នាំទៅរកការលាតត្រដាងការពិត" ដែរឬយ៉ាងណាតែប៉ុណ្ណោះ។ នៅត្រង់កថាខណ្ឌទីបីនៃដីកាសម្រេច សហចៅក្រមស៊ើបអង្កេតបានអះអាងយ៉ាងត្រឹមត្រូវថា "សហចៅក្រមស៊ើបអង្កេតសូមបញ្ជាក់ឡើងវិញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវការវិភាគតាមផ្លូវច្បាប់ទៅលើឯកសារដែលបានស្នើទាំងនោះ ក្នុងការសម្រេចថា តើឯកសារទាំងនោះអាចជួយលាតត្រដាងការពិតបានដែរឬយ៉ាងណា"។ ដូច្នេះ ពួកគាត់បានយល់ដឹងអំពីករណីយកិច្ចរបស់ខ្លួនក្នុងរឿងនេះ។ នៅក្នុងកថាខណ្ឌទីប្រាំ ការយោងទៅលើ "ភាពពាក់ព័ន្ធ" ពុំបានបញ្ជាក់ថាការពិតឯកសារទាំងនោះត្រូវបានវាយតម្លៃដោយឈរលើមូលដ្ឋាននៃការធ្វើតេស្តត្រឹមត្រូវនោះទេ ទោះបីជាមានការបញ្ជាក់ក្នុងកថាខណ្ឌទីបីនៃដីកាសម្រេចនោះក៏ដោយ។ សេចក្តីសង្ខេបនៃកថាខណ្ឌទីប្រាំដែលជាកថាខណ្ឌគោល ពាក់ព័ន្ធនឹងការបដិសេធឯកសារទាំងនោះ បញ្ជាក់

[១២] បណ្តឹងឧទ្ធរណ៍កថាខណ្ឌ៤/ក។



អង្គជំនុំជម្រះសាលាដំបូង ... PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00533226



ថា មិនអាចមានមូលដ្ឋានពិតប្រាកដសម្រាប់ការពិចារណាចំពោះឯកសារ ដែលបានកំណត់ភិនភាគរួច ហើយទាំងនោះទេ។ ជាឧទាហរណ៍ ពួកគេពុំអាចធ្វើការបញ្ជាក់បានថាតើឯកសារណាខ្លះដែលត្រូវបាន បដិសេធ ដោយផ្អែកលើមូលដ្ឋាននៃភាពខ្វះ "ភាពពាក់ព័ន្ធនៅក្រោមវិសាលភាពនៃកិច្ចស៊ើបសួរបច្ចុប្បន្ន" និងថាតើឯកសារណាខ្លះដែល "ត្រូវបានសម្រេចថា ជាឯកសារដែលរៀបរាប់តែអំពីបញ្ហាទូទៅពេក" នោះ។

២២ សហចៅក្រមស៊ើបអង្កេតបានលើកឡើងក្នុងដីកាសម្រេចអំពីសម្អាងហេតុគ្រប់គ្រាន់ ដើម្បីបង្ហាញអំពី ការវិភាគរបស់ខ្លួនពាក់ព័ន្ធនឹងឯកសារដែលបានស្នើឡើងទាំងនោះ[១៣]។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះ គ្មានលទ្ធភាពដើម្បីពិចារណាឲ្យបានត្រឹមត្រូវលើភាពសមស្រប ឬការរកឃើញនៃអង្គហេតុដែលនាំទៅ រកការទាញសេចក្តីសន្និដ្ឋាននៅក្នុងកថាខណ្ឌទីប្រាំនៃដីកាសម្រេចនោះ និងការអនុវត្តឆន្ទានុសិទ្ធិត្រឹមត្រូវ របស់ពួកគាត់បាននោះទេ។

២៣ វិធាន ៥៥(១០) ដែលពាក់ព័ន្ធចែងទាក់ទិននឹងដីកាសម្រេចបដិសេធសំណើដូច្នេះថា "... ដីកាបដិសេធ នេះត្រូវមានសម្អាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី និងបើកផ្លូវប្តឹងឧទ្ធរណ៍"។

២៤ ភាគីមានសិទ្ធិជាមូលដ្ឋានដើម្បីបានទទួលដំណឹងអំពីហេតុផលនៃសេចក្តីសម្រេចណាមួយ។ ប្រការនេះ អនុញ្ញាតឲ្យភាគីបានដឹងអំពីមូលដ្ឋាននៃសេចក្តីសម្រេចនីមួយៗ ដែលធ្វើឲ្យភាគីរងគ្រោះស្ថិតក្នុងស្ថាន ភាពមួយដែលអាចកំណត់បានថាតើនឹងដាក់ប្តឹងឧទ្ធរណ៍ដែរឬយ៉ាងណា និងប្តឹងលើមូលដ្ឋានអ្វី។ ដូចគ្នា នេះដែរ ភាគីដែលឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍មានសិទ្ធិទទួលបានការជូនដំណឹងអំពីសម្អាងហេតុ ដើម្បី ឲ្យខ្លួនអាចត្រៀមរៀបចំការឆ្លើយតបរបស់ខ្លួនឲ្យបានត្រឹមត្រូវ និងពាក់ព័ន្ធ។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

---

១៣ នៅក្នុងសាលដីការបស់ខ្លួនក្នុងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ទាក់ទងនឹងសំណើសុំមោឃភាព អង្គបុរេជំនុំជម្រះយល់ ឃើញថា "សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឲ្យផ្តល់សំអាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ"។ សាលដីកាលើ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ២១។

២៥ លើសពីនេះទៅទៀត វិធាន៧៧(១៤) តម្រូវឲ្យអង្គបុរេជំនុំជម្រះចេញសេចក្ដីសម្រេចដោយ "មានសម្អាងហេតុ"។ ប៉ុន្តែ ពុំមានតុលាការសាលាឧទ្ធរណ៍ណាមួយ អាចធ្វើសេចក្ដីសម្រេចដោយមានសម្អាងហេតុដូច្នេះបាននោះទេ ដ្បិតដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នេះ ពុំមានបង្ហាញយុត្តិកម្ម និងភាពសមហេតុផលរបស់ខ្លួនផងនោះ។ អង្គបុរេជំនុំជម្រះសូមយោងបន្ថែមទៀតទៅលើកិច្ចពិភាក្សាចំពោះបញ្ហានេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំកិច្ចស៊ើបសួរ" ដោយក្រុមមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១០[១៤]។

២៦ អង្គបុរេជំនុំជម្រះរកឃើញថា សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសឆ្គងផ្នែកច្បាប់ ដោយសារតែកថាខណ្ឌទីប្រាំនៃដីកាសម្រេចនោះ ពុំបានបង្ហាញសម្អាងហេតុអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការដែលពួកគាត់សម្រេចបដិសេធឯកសារទាំងឡាយ ដូចមានយោងក្នុងសំណើនោះ។ បញ្ហាគឺពាក់ព័ន្ធនឹងសហចៅក្រមស៊ើបអង្កេតក្នុងការពិចារណារបស់ខ្លួនលើបញ្ហានេះតែមួយគត់ និងការផ្ដល់សម្អាងហេតុសម្រាប់ការបដិសេធសំណើឲ្យអនុលោមតាមច្បាប់។

២៧ ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះមិនត្រូវពិចារណាបន្ថែមលើមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នោះទេ ដ្បិតបើធ្វើដូច្នេះវាអាចនាំឲ្យមានការប៉ាន់ស្មានអំពីសម្អាងហេតុសម្រាប់ការបដិសេធសំណើនោះ។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ៖**

១ ទទួលយកបណ្ដឹងឧទ្ធរណ៍នេះ។

២ បង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតផ្ដល់សម្អាងហេតុតាមច្បាប់ ពាក់ព័ន្ធនឹងសេចក្ដីសម្រេចបដិសេធមួយផ្នែកនៃសំណើដូចមានបញ្ជាក់ក្នុងកថាខណ្ឌទីប្រាំ នៃដីកាសម្រេចរបស់ខ្លួននោះឲ្យបានក្នុងរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងនៃសេចក្ដីសម្រេចនេះ។

---

[១៤] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំកិច្ចស៊ើបសួរ" ដោយក្រុមមេធាវីការពារក្ដីរបស់លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១០ ឯកសារលេខៈD353/2/3 ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ២២ ដល់កថា ខណ្ឌ២៨។

៣ ក្នុងរយៈពេលពីរថ្ងៃ គិតចាប់ពីថ្ងៃដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងទៅភាគីអំពីសម្អាងហេតុទាំងនេះ ភាគីប្តឹងឧទ្ធរណ៍ត្រូវជម្រាបមកអង្គបុរេជំនុំជម្រះ និងភាគីដទៃទៀតនៃបណ្តឹងឧទ្ធរណ៍នេះជាលាយលក្ខណ៍អក្សរស្តីពីចេតនារបស់ខ្លួន ថាតើចង់បន្តកិច្ចដំណើរការនីតិវិធីនេះតទៅទៀត ឬសុំដកបណ្តឹងឧទ្ធរណ៍ទៅវិញ។

៤ ប្រសិនបើភាគីប្តឹងឧទ្ធរណ៍ជូនដំណឹងអំពីចេតនាចង់បន្តកិច្ចដំណើរការនីតិវិធីតទៅទៀតនោះ ខ្លួននឹងមានរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងអំពីចេតនាចង់បន្តកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដើម្បីធ្វើសារណាជាលាយលក្ខណ៍អក្សរបន្ថែម។ ភាគីដទៃទៀតនៃបណ្តឹងឧទ្ធរណ៍នឹងមានរយៈពេលបីថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងនៃសារណាជាលាយលក្ខណ៍អក្សរនៃភាគីប្តឹងឧទ្ធរណ៍ ដើម្បីឆ្លើយតបជាលាយលក្ខណ៍អក្សរ។ ភាគីប្តឹងឧទ្ធរណ៍អាចឆ្លើយតបទៅនឹងសារណាតបណាមួយបាន ក្នុងអំឡុងពេលពីរថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងរបស់ខ្លួន។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។៚

ភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **ន័យ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**